Living the Lotus
Buddhism in Everyday Life
New Year's Issue

# ធ្វើដំណើរឆ្ពោះទៅមុខដោយគោរពតាមប្រវត្តិសាស្ត្រនិងប្រពៃណីទំនៀមទម្លាប់

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីហ្សូកូសេកៃ

## សំដៅទៅកាន់ខួបគម្រប់ ១០០ ឆ្នាំរបស់យើង សមាជិកទាំងអស់រួបរួមគ្នាជាធ្លុងមួយខិតខំឱ្យអស់ពីសមត្ថភាពក្នុងការចិញ្ចឹមបីបាច់កុមារនិងយុវជន

សួស្តីឆ្នាំថ្មី!

ចូរយើងធ្វើឱ្យមួយឆ្នាំនេះក្លាយជាមួយឆ្នាំមួយដែលពោរពេញទៅដោយសេចក្តីព្យាយា មយ៉ាងស្វាហាប់ជាមួយនឹងទឹកចិត្តដ៏ថ្មីស្រ ឡាង ។

តួអក្សរចិន新(ថ្មី) ក្នុងពាក្យ "新年(ឆ្នាំថ្មី)" គឺជាការរួមបញ្ចូលគ្នានៃតួអក្សរ "辛" (ភាពលំបាក), អក្សរ"木" (ឈើ) និងអក្សរ "斤" (ពូថៅ)។ "ភាពលំបាក(辛)" តំណាងឱ្យសេចក្តីលំបាកហត់នឿយ និងការខិតខំប្រឹងប្រែងតស៊ូ ខណៈដែលអក្សរ "斤 (ពូថៅ)" សំដៅទៅលើពូថៅធំដែលគេប្រើសម្រាប់កាប់ឈើ។ ពោលគឺការស្រឡាញ់និងបីបាច់ថែរក្សាឈើ ខិតខំធ្វើការកែច្នៃវាហើយបង្កើតអ្វីមួយថ្មីដើម្បីប្រើប្រាស់។

បើនិយាយចំពោះពិភពមនុស្ស វាមានន័យថារៀនសូត្រពីប្រវត្តិសាស្ត្រនិងប្រពៃណីទំនៀមទម្លាប់ដែលបុព្វបុរសរបស់យើងបានកសាងឡើងព្រមទាំងគោរពហើយស្របពេលជាមួយគ្នានោះប្រើភាពច្នៃប្រឌិតដែលសមស្របទៅនឹងសម័យកាលទំនើបខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីបង្កើតអ្វីដែលថ្មី។

ចូរយើងនាំគ្នាពិចារណាយ៉ាងស៊ីជម្រៅអំពីអត្ថន័យសំខាន់ដែលបង្កប់នៅក្នុងតួអក្សរ "新" (ថ្មី) នៅពេលដែលយើងធ្វើដំណើរឆ្ពោះទៅមុខជាមួយគ្នានៅឆ្នាំនេះ។

ឥឡូវនេះ ខ្ញុំព្រះករុណាអាត្មាភាពសូមគូសបញ្ជាក់ពី «គោលនយោបាយសម្រាប់ឆ្នាំទី ៨ នៃសករាជរ៉េយវ៉ា (ឆ្នាំ ២០២៦) » របស់យើងដូចខាងក្រោមនេះ៖

កាលពីឆ្នាំមុនប្រទេសជប៉ុនបានប្រារព្ធខួបទី១០០ នៃសករាជស្វូវ៉ា។ សមាគមរបស់យើងដែលបង្កើតឡើងនៅឆ្នាំ ១៩៣៨ (សករាជស្វូវ៉ាទី១៣) នឹងប្រារព្ធខួបលើកទី១០០ របស់ខ្លួននៅឆ្នាំ ២០៣៨ ពោលគឺ ១២ ឆ្នាំក្រោយគិតចាប់ពីពេលនេះតទៅ។

គិតមកដល់ចំណុចនេះ នៅឆ្នាំនេះផងដែរ ចូរយើងបន្តធ្វើការងារដោយរីករាយ និងសហការគ្នាជារៀងរាល់ថ្ងៃតាមរយៈជីវិតនៃជំនឿទៅលើសាសនាព្រះពុទ្ធរបស់យើង នាំគ្នាគិតអំពីវិធីសម្រាប់ណែនាំកុមារនិងយុវជនដែលជាទំពាំងស្នងឫស្សី និងជាអ្នកដែលនឹងទទួលខុសត្រូវចំពោះអនាគតកាល ឱ្យឆ្ពោះទៅរកមនុស្សធម៌,គិតពីវិធីដែលយើងអាចជួយបង្កើតចរិតលក្ខណៈរបស់ពួកគេនិងពីវិធីដែលយើងអាចនាំមកនូវសណ្តាប់ធ្នាប់ដល់ក្រុមគ្រួសារនិងគេហដ្ឋានរបស់យើងហើយលើសពីនេះទៅទៀតគឺវិធីទទួលយកមរតកប្រពៃណីជប៉ុន



ហើយកសាងប្រទេសជាតិដ៏អស្ចារ្យមួយ។

នៅឆ្នាំ ២០១៨ ក្នុងឱកាសខួបលើកទី ៨០ របស់សមាគមយើង ខ្ញុំព្រះករុណាអាត្មាភាពបានបញ្ជាក់ដោយសម្លឹងមើលទៅខួបលើកទី ១០០ ខាងមុខនេះថា កាតព្វកិច្ចសំខាន់របស់យើងគឺខិតខំប្រឹងប្រែងចំពោះបេសកកម្មជាមូលដ្ឋាននៃការបណ្តុះបណ្តាល(ចិញ្ចឹមបីបាច់) មនុស្ស។

ការណែនាំកុមារ និងយុវជនដែលជាទំពាំងស្នងឬស្សីនាអនាគត ឱ្យមានសិលធម៌(ដោយដើរតាមមាគ៌ាពោធិសត្វ) និងការលើកកម្ពស់ការអភិវឌ្ឍចរិតលក្ខណៈរបស់ពួកគេគឺជាបញ្ហាមួយដែលគួរតែត្រូវបានផ្តល់អាទិភាពខ្ពស់បំផុត មិនត្រឹមតែសម្រាប់សមាគមរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់សង្គមទាំងមូលផងដែរ។

ដូចដែលយើងទាំងអស់គ្នាបានដឹងរួចមកហើយថាគោលនយោបាយជាមូលដ្ឋានរបស់សមាគមយើងគឺ "រក្សាគ្រួសារនិងគេហដ្ឋានឱ្យមានសណ្តាប់ធ្នាប់"។ នេះគឺដោយសារតែគ្រួសារនិងគេហដ្ឋានគឺជាទីកន្លែងសម្រាប់បណ្តុះបណ្តាលមូលដ្ឋានទៅលើការអភិវឌ្ឍចរិតលក្ខណៈរបស់មនុស្ស។

ជីវិតរបស់ឪពុកម្តាយផ្តោតលើការថ្វាយបង្គំព្រះពុទ្ធរូបដែលតម្កល់លើអាសនៈ គ្រួសារមានភាពរីករាយ មានសេចក្តីសប្បុរសនិងការប្រើពាក្យសម្តីប្រកបទៅដោយភាពកក់ក្តៅជាប្រចាំទៅលើកូនៗមានឥទ្ធិពលយ៉ាងច្បាស់ លាស់ទៅលើការអភិវឌ្ឍចរិតលក្ខណៈរបស់កុមារ ។

អ្វីដែលសំខាន់ជាពិសេសគឺទំនាក់ទំនងជាមួយកូនៗតាំងពីកុមារភាព ពោលគឺ ការអប់រំនៅផ្ទះ។

«បុណ្យស៊ីជី-ហ្គោ-សាំង» (បុណ្យកុមារអាយុ ៧ឆ្នាំ ៥ឆ្នាំ និង៣ឆ្នាំ) ត្រូវបានគេស្គាល់ថាជាព្រឹត្តិការណ៍ប្រពៃណីរបស់ជប៉ុន ហើយគេគិតថា អាយុ៧ឆ្នាំ ៥ឆ្នាំ និង៣ឆ្នាំ តំណាងឱ្យរយៈពេលនៃការអប់រំនៅផ្ទះដែលចាំបាច់បំផុតមុនពេលកូនៗចូលសាលារៀន។

ខួរក្បាលរបស់កុមារមានភាពបរិសុទ្ធនិងមុតស្រួចបំផុតចាប់ពីអាយុប្រហែល១០ឆ្នាំរហូតដល់អាយុ១៣ ឬ១៤ឆ្នាំ។ ភ្នែករបស់កុមារល្អបំផុតនៅរវាងអាយុ៩ និង១០ឆ្នាំ។ ជាអាយុដែលគេតែងតែនិយាយថា «ភ្នែកក្មេងនោះអាចមើលឃើញមុតណាស់ សឹងតែថាមើលក្រដាសធ្លុះពីម្ខាងទៅម្ខាង»។ ការស្រមើស្រមៃ,ការចេះផ្សារភ្ជាប់ព្រឹត្តិការណ៍មួយទៅនឹងព្រឹត្តិការណ៍មួយផ្សេងមួយទៀតដោយប្រើមនោគតិនិងប្រាជ្ញា (Association) និងការចងចាំមានខ្លាំងបំផុតនៅអាយុ១១ ឬ ១២ឆ្នាំ ហើយកុមារក្លាយជាបុគ្គលដែលមានភាពជាមនុស្សពេញលេញនៅអាយុ១៥ ឬ១៦ឆ្នាំ។

យើងត្រូវតែចងចាំថា ប្រសិនបើយើងជាឪពុកម្តាយមិនបានផ្តល់ការអប់រំនៅផ្ទះឱ្យបានគ្រប់គ្រាន់ក្នុងអំឡុងពេលដ៏សំខាន់ទាំងនេះហើយប្រគល់វាទាំងស្រុងទៅឱ្យការអប់រំនៅសាលារៀន យើងមិនអាចសង្ឃឹមថានឹងអាចអភិវឌ្ឍយុវជនបានត្រឹមត្រូវនោះទេ។ បញ្ហាសង្គមផ្សេងៗដែលកុមារនិងយុវជនប្រឈមមុខវាអាស្រ័យលើការយល់ដឹងការទទួលខុសត្រូវនិងសកម្មភាពរបស់ឪពុកម្តាយ។និយាយបែបនេះមិនមែនជាការបំផ្លើសឡើយ។

មាននរណាម្នាក់ធ្លាប់បាននិយាយថា "នយោបាយ និងសេដ្ឋកិច្ចមានសម្រាប់តែការអប់រំយុវជនប៉ុណ្ណោះ"។ម្យ៉ាងវិញទៀត មនុស្សចាស់ត្រូវតែកសាងសង្គមមួយដែលមានអំណោយផលដល់ការអភិវឌ្ឍប្រកបទៅដោយសុខភាពទាំងផ្លូវកាយនិងបញ្ញារបស់យុវជន។



ស្រុកកំណើតនៃសមាគមរបស់យើង។ នៅមុខអាសនៈដ៏ពិសិដ្ឋនៅសាលហ្វឹកហ្វឺន។

សាលហ្វឹកហ្វឺនត្រូវបានបើកសម្ពោធនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៤៨ ហើយបានបម្រើការជាទីស្នាក់ការកណ្តាលរបស់សមាគមរហូតដល់ព្រះវិហារធំបានកសាងនៅឆ្នាំ ១៩៦៤។ សូម្បីតែបន្ទាប់ពីឈ្មោះនេះត្រូវបានប្តូរទៅជាឈ្មោះបច្ចុប្បន្នរបស់ខ្លួននៅខួបទី ៣០ នៃការសាងសង់នៅឆ្នាំ ១៩៩៤ក្តីក៏សមាជិកនៅតែបន្តប្រើពាក្យថា "ទីស្នាក់ការចាស់" ហើយទីនោះនៅតែជាកន្លែងដែលសមាជិកចាត់ទុកថាជាទីជម្រកដ៏កក់ក្តៅរបស់ពួកគេ។បន្ទាប់ពីគ្រោះរញ្ជួយដីដ៏ធំនៅភាគខាងកើតប្រទេសជប៉ុនក្នុងឆ្នាំ ២០១១ ការងារពង្រឹងភាពធន់នឹងគ្រោះរញ្ជួយដីត្រូវបានអនុវត្ត។ នៅពេលនោះ ដោយសង្ឃឹមថាអ្នកមកគោរពបូជាអាចទទួលបានបទពិសោធន៍បរិយាកាសនៃសម័យកាលហ្វឹកហ្វឺនពីមុន ច្បាប់ចម្លងនៃ "មហាយ័ន្ត្រ Great Mandala" ដែលចារដោយដៃផ្ទាល់របស់ដោយស្ថាបនិកកៃស្សូសាម៉ា នីវ៉ាណូ នីជីយេ ដែលបានតម្កល់ទុកនៅក្នុងសាលវិមានអេជូដិងរបស់វិហារក្នុងឆ្នាំ ១៩៦៣ ត្រូវបានយកមកដាក់តាំងនៅពីមុខអាសនៈ។

វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់យុវជនជំនាន់ក្រោយក្នុងការរស់នៅដោយមោទនភាពចំពោះប្រទេសជាតិរបស់ពួកគេ។ ប្រសិនបើមនុស្សអាចឱ្យតម្លៃនិងគោរពប្រទេសរបស់ពួកគេការអភិវឌ្ឍយុវជននឹងរីកចម្រើនដោយធម្មជាតិ។

ជាពិសេស ប្រទេសជប៉ុនគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានប្រវត្តិសាស្ត្រ និងប្រពៃណីដ៏វែងបំផុត។ ជនជាតិជប៉ុនមានព្រះចៅអធិរាជនិងព្រះរាជបល្ល័ង្កជាជម្រកដ៏កក់ក្ដៅដែលមិនអាចប្រៀបផ្ទឹមបាននៅក្នុងពិភពលោក។ ចាប់តាំងពីការបង្កើតប្រទេសជាតិមក ប្រជាជនជប៉ុនបានរស់នៅដោយសុខដុមរមនានិងបានកសាងវប្បធម៌ខាងវិញ្ញាណនិងស្មារតីដ៏សម្បូរបែប។

លើសពីនេះទៅទៀត នៅសម័យបុរាណ ប្រទេសជប៉ុនបានដាក់ឈ្មោះប្រទេសរបស់ខ្លួនថា "យ៉ាម៉ាតូ（Yamato）" ហើយបានប្រកាន់ខ្ជាប់នូវស្មារតីនៃ "សន្តិភាពដ៏អស្ចារ្យ" និង "ភាពសុខដុមរមនាដ៏អស្ចារ្យ" ទុកជាឧត្តមគតិជាតិរបស់ខ្លួន។

ព្រះអង្គម្ចាស់ហ្សូតុគឹ（Shotoku） បានបញ្ចូលពាក្យ "ឱ្យតម្លៃទៅលើភាពសុខដុមរមនា" នៅក្នុងមាត្រា ទី១ នៃរដ្ឋធម្មនុញ្ញដែលមាន១៧មាត្រានៅជំនាន់នោះ។

ការបន្តប្រពៃណីរបស់ប្រទេសជប៉ុនដែលឱ្យតម្លៃទៅលើសន្តិភាព និងភាពសុខដុមរមនា ព្រមទាំងការខិតខំកសាងប្រទេសជាតិដ៏អស្ចារ្យមួយមានសារៈសំខាន់ខ្លាំងណាស់បើមើលពីទស្សនៈនៃ"ការបណ្ដុះបណ្ដាល មនុស្ស"។

**ការដឹងគុណនិងរកឃើញន័យនៃជីវិតរបស់យើងហើយដើរតាមមាគ៌ាព្រះពោធិសត្វគឺជាការចង់បានបំផុតនៃព្រះសម្មាសម្ពុទ្ធ**

ដោយយើងបានដាក់គោលដៅទៅលើការប្រារព្ធខួបលើកទី ១០០ របស់សមាគមយើងក្នុងរយៈពេល ១២ ឆ្នាំខាងមុខ សមាជិកទាំងអស់រួបរួមគ្នាហើយខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីបណ្ដុះបណ្ដាលកុមារ និងយុវជនយោលទៅតាមតួនាទីនីមួយៗរបស់ខ្លួន។

កាលពីឆ្នាំមុន ខ្ញុំព្រះករុណាអាត្មាភាពមានអាយុ ៨៨ ឆ្នាំ ជប៉ុនគេហៅថា"beiju"មានន័យត្រង់ៗថាអាយុអង្ករតាមការរាប់អាយុបែបប្រពៃណីរបស់ជប៉ុន។ តាំងពីថ្ងៃទី ២០ ខែមីនា សមាជិកនៃសមាគមរបស់យើងបានរៀបចំ "ការជួបជុំអបអរសាទរ" សរុបទាំងអស់មានចំនួនប្រាំបីនៅវិហារសម្រាប់"beiju"អាត្មាភាព។

ក្នុងអំឡុងពេលនៃការជួបជុំទាំងនេះ ខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ថាបានទទួលការលើកទឹកចិត្តយ៉ាងពិតប្រាកដនៅរាល់ពេលដែលឮសមាជិកម្នាក់ៗនិយាយថា"ខ្ញុំពិតជារីក រាយណាស់ដោយបានចូលរួមជាមួយ រីហ្សូកូសេកៃ"។ ខ្ញុំព្រះករុណាអាត្មាភាពមានការរំជួលចិត្តយ៉ាងខ្លាំងដោយបានដឹងថាយើងទាំងអស់គ្នាបានរីកចម្រើនមួយជំហានៗក្នុងនាមជាសមាជិករីហ្សូកូសេកៃ។ លើសពីនេះទៅទៀតខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ដូចជាមានសាច់ញាតិមកពីគ្រប់ទិសទីនៃប្រទេសមកជួបជុំគ្នាដើម្បីអបអរសាទរជាមួយគ្នា ហើយបេះដូងរបស់ខ្ញុំព្រះករុណាអាត្មាភាពបានពោរពេញដោយអារម្មណ៍កក់ក្ដៅនឹងអំណរគុណ។ សូមអរគុណអ្នកទាំងអស់គ្នា។

មនុស្សយើងគ្រប់គ្នាដោយគ្មានករណីលើកលែង សុទ្ធតែចាស់ទៅ។ នេះជាច្បាប់នៃធម្មជាតិ។ ទោះបីជាយ៉ាងនេះក្ដីមនុស្សជាច្រើនមិនចង់ចាស់ហើយព្យាយាមគេចពីវា។ ទោះជាយ៉ាងណាក៏ដោយ គេនិយាយថាដរាបណាអ្នកមិនចូលចិត្តភាពចាស់ជរា អ្នកនៅមិនទាន់ទៅជាមនុស្សពេញវ័យនៅឡើយទេ។

ការកើនអាយុទៅជាមនុស្សចាស់មិនមែនគ្រាន់តែជាដំណើរការនៃការឡើងចាស់ដោយអាយុនោះទេ។បុព្វបុរសយើងបានប្រាប់ថាវាគឺជាដំណើរការនៃការប្រមូលផ្តុំបទពិសោធន៍ ការសញ្ជឹងគិតកាន់តែស៊ីជម្រៅ និងការខិតខំធ្វើឱ្យចរិតលក្ខណៈរបស់មនុស្សម្នាក់ឡើងល្អឥតខ្ចោះហើយនេះគឺជាធម្មជាតិពិតរបស់មនុស្សដែលយើងម្នាក់ៗតោងតែយល់ពីអត្ថន័យដ៏ជ្រាលជ្រៅហើយមានមោទនភាពនឹងវា។

ជាការពិតណាស់ គ្មានអ្វីដែលហៅថា "បានពេញលេញហើយ " នោះទេ។ នោះហើយជាមូលហេតុដែលយើងត្រូវតែរៀនសូត្រជានិច្ច និងបន្តខិតខំកែលម្អខ្លួនយើងជាមនុស្សជានិច្ចជាកាល។ មីយ៉ាហ្សាវ៉ា គេនជី（Miyazawa Kenji） បាននិយាយថា "ភាពមិនពេញលេញអស់កល្បជានិច្ចគឺជាភាពពេញលេញ"។ យើងមិនគួរសន្មតងាយៗថាយើងយល់អ្វីមួយច្បាស់ហើយនោះទេ ប៉ុន្តែត្រូវចំណាយពេលពេញមួយជីវិតរបស់យើងដើម្បីស្វែងរកមាគ៌ា។

ពេលក្រឡេកមើលទៅក្រោយនៅកាលនៅពីក្មេងខ្ញុំព្រះករុណាអាត្មាភាពបានបះបោរប្រឆាំងនឹងជំនឿរបស់រីហ្សូកូសេកៃ ។ ទោះជាយ៉ាងណាក៏ដោយនៅពេលដែលខ្ញុំព្រះករុណាអាត្មាភាពទទួលបានបទពិសោធន៍មួយត្រួតលើមួយ និងការសិក្សារៀនសូត្រ ខ្ញុំព្រះករុណាអាត្មាភាពក៏ចាប់ផ្ដើមយល់យ៉ាងច្បាស់អំពីស្មារតីដែលព្រះសម្មាសម្ពុទ្ធសក្យមុនី



គោតមចង់បង្ហាញដល់យើង។ ហើយចាប់ពីពេលដែលខ្ញុំព្រះករុណាអាត្មាភាពចូលដល់វ័យចំណាស់នេះមក ខ្ញុំព្រះករុណាអាត្មាភាពបានយល់ជាក់ដោយខ្លួនប្រាណនិងបេះដូងផ្ទាល់ពីធម៌ព្រះពុទ្ធឬបើនិយាយឱ្យសាមញ្ញគឺការបង្រៀនប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ។

មានវគ្គសំខាន់មួយនៅក្នុងគម្ពីរធម្មបទ ដែលអ្នកទាំងអស់គ្នាប្រហែលជាបានស្គាល់ច្បាស់រួចហើយគឺ៖

«ជាការពិបាកណាស់នឹងអាចទទួលបានជីវិតជាមនុស្ស ហើយទោះបីជាយើងនឹងស្លាប់នៅទីបំផុតក៏ដោយក៏ការមានជីវិតរស់នៅឥឡូវនេះវាមានតម្លៃណាស់ ។ ជាការកម្រណាស់នឹងបានជួបព្រះធម៌ពិត ហើយវាមានតម្លៃណាស់ក្នុងការចាប់កំណើតមកក្នុងពិភពលោកដែលមានវត្តមានព្រះពុទ្ធនៅគ្រប់ទីកន្លែងក្នុងលោកនេះ»។

បើនិយាយឲ្យងាយស្តាប់ទៅគឺថា "មិនងាយឡើយនឹងទទួលបាននូវជីវិតជាមនុស្ស ហើយវាជាការកម្រណាស់ចំពោះមនុស្សម្នាក់ដែលគេកំណត់មកថាត្រូវតែស្លាប់ហើយអាចរស់រានមានជីវិតនៅពេលនេះ។ ទោះបីជាមនុស្សម្នាក់ត្រូវបានផ្តល់ជីវិតមកឱ្យក៏ដោយក៏ជាការ កម្រណាស់នឹងបានជួបការបង្រៀនប្រៀនប្រដៅត្រឹមត្រូវ (ធម៌ព្រះពុទ្ធ) ក្នុងមួយជីវិតរបស់គេហើយក៏ជាការកម្រដែលមិនងាយមានដែរសម្រាប់មនុស្សម្នាក់ដែលបានកើតមកលើផែនដី ដែលពោរពេញទៅដោយព្រះពុទ្ធនេះ"។

ខ្ញុំព្រះករុណាអាត្មាភាពជឿថានៅក្នុងពាក្យពីរបីម៉ាត់នេះមានពោរពេញទៅដោយការបង្រៀនប្រៀនប្រដៅរបស់ព្រះពុទ្ធ។

ជីវិតរបស់យើងពិតជាអាថ៌កំបាំង មានតម្លៃ និងដឹងគុណណាស់។ ហើយវាកម្រណាស់ក្នុងការជួបប្រទះនឹងការបង្រៀនប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ការដឹងពីរឿងនេះនាំទៅរកការរកឃើញគោលបំណងសំខាន់បំផុតនិងន័យនៃជីវិត។

បើបានជាទទួលបាននូវជីវិតនេះហើយជាជាងរស់នៅដោយរអ៊ូរទាំ ខ្ញុំព្រះករុណាអាត្មាភាពយល់ថាការទទួលយកការបង្រៀនប្រៀនប្រដៅរបស់ព្រះពុទ្ធ (ធម៌ព្រះពុទ្ធ) និងការរស់នៅដោយជំនឿទៅលើព្រះពុទ្ធសាសនាមានន័យថារស់



នៅដោយរីករាយនិងដឹងគុណចំពោះជីវិតដែលបានផ្តល់មកឱ្យយើង។

ជាការពិតណាស់ ជីវិតមានអមទៅដោយសេចក្តីព្រួយបារម្ភ និងទុក្ខវេទនាផ្សេងៗ។ ប៉ុន្តែនៅពេលដែលយើងដឹងថាយើងទទួលបានពរជ័យទាំងប៉ុន្មានដែលបានរៀបរាប់មកនេះ យើងចាប់អារម្មណ៍ថាទទួលបាននូវការលើកទឹកចិត្តឱ្យបន្តឈានជើងទៅមុខរស់នៅដោយមិនបោះបង់ចោល។ យើងចាប់ផ្តើមស្វែងរកការដឹងគុណ សូម្បីតែនៅក្នុងបាតុភូតដែលយើងធ្លាប់ចាត់ទុកថាមិនល្អក៏ដោយ។

ចុះទម្រាំបើយើងត្រូវបានទទួលការបង្រៀនថា យើងទាំងអស់គ្នាមានធាតុព្រះពុទ្ធដូចគ្នា ហើយត្រូវបានប្រទាននូវសមត្ថភាពក្នុងការទទួលស្គាល់សច្ចធម៌ និងការបង្រៀនប្រៀនប្រដៅរបស់ព្រះពុទ្ធក៏ដូចជាសមត្ថភាពក្នុងការដោះស្រាយបញ្ហាដោយខ្លួនឯងទៅទៀត?

ដូច្នេះ ជំនួសការនិយាយថា «ខ្ញុំមិនល្អគ្រប់ដប់ទេ» ឬ «ខ្ញុំមិនអាចធ្វើវាបានទេ» ក្នុងនាមជាពុទ្ធសាសនិកចំណុចចាប់ផ្តើមសម្រាប់ការរស់នៅដ៏មានសុភមង្គលគឺការទទួលយក និងអនុវត្តតាមការបង្រៀនប្រៀនប្រដៅរបស់ព្រះពុទ្ធដោយបានបទ។

ឥឡូវនេះ យើងអាចកម្រើកដៃ និងជើងរបស់ខ្លួនបាន ហើយអាចដកដង្ហើម និយាយ និងទទួលទានអាហារបាន។ ខ្យល់ និងទឹកដែលចាំបាច់សម្រាប់ជីវិតមិនមែនជារបស់ដែលយើងបង្កើតទេ វាគឺជាពរជ័យពីធម្មជាតិ។ ហើយយើងរស់បានដោយសារការគាំទ្រពីមនុស្សជាច្រើន។ ការក្លាយជាមនុស្សម្នាក់ដែលចេះដឹងគុណចំពោះអ្វីៗទាំងអស់ក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន តាមពិតទៅ គឺការសម្រេចបាននូវសុភមង្គលដ៏អស្ចារ្យបំផុត។

កើតមកជាមនុស្សយើងត្រូវបានទ្រទ្រង់ និងរក្សាជីវិតឱ្យនៅរស់ដោយអ្វីៗទាំងអស់ពីចក្រវាល។យើងត្រូវតែដឹងគុណចំពោះអ្វីៗទាំងនេះហើយរស់ប្រកបដោយអត្ថន័យដោយដើរតាមមាគ៌ាព្រះពោធិសត្វ។ ឥឡូវនេះនាអាយុ ៨៩វស្សា (តាមការគណនារបស់ជប៉ុន) ខ្ញុំព្រះករុណាអាត្មាភាពបានយល់យ៉ាងពិតប្រាកដថា នេះគឺជាបំណងប្រាថ្នាដ៏អស្ចារ្យបំផុតរបស់ព្រះពុទ្ធ ។

ប្រសិនបើ យើងអាចឆ្លាក់រឿងនេះយ៉ាងជ្រៅនៅក្នុងចិត្តរបស់យើងជាមួយគ្នានឹងពុទ្ធសាស និកទាំងអស់ នោះជីវិតប្រាកដជានឹងមានអត្ថន័យមិនលែងឡើយ។

ក្នុងរយៈពេលពីរឆ្នាំទៀត សមាគមរបស់យើងនឹងប្រារព្ធខួបលើកទី៩០របស់ខ្លួន ហើយ ១២ ឆ្នាំក្រោយទៀត នៅឆ្នាំ ២០៣៨ យើងនឹងប្រារព្ធខួបលើកទី១០០នៃការបង្កើតសមាគមសាសនារបស់យើង។

តាមរយៈជីវិតនៃជំនឿរបស់យើង យើងសង្ឃឹមយ៉ាងមុតមាំថានឹងជំរុញការអភិវឌ្ឍចរិតលក្ខណៈរបស់កុមារតូចៗ និងយុវជនជាបន្តបន្ទាប់តាមរយៈគ្រួសារនិងដើម្បីកសាងប្រទេសជាតិដ៏សុខសាន្តមួយដែលទទួលមរតកប្រពៃណីរបស់ប្រទេសជប៉ុន។